ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ២៨៣ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## គោលការណ៍និងនីតិវិធីបន្ថែមសម្រាប់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធក្នុងក្របខ័ណ្ឌនៃការផ្ទេរមុខងារ និងការចែករំលែកចំណូលមិនមែនសារពើពន្ធ ពីរដ្ឋបាលថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨២២/០១០ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ

- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី២ ខែមេសា ឆ្នាំ២០០២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១២ ស្តីពីដំណើរការទូទៅនៃការផ្ទេរមុខងារ និងធនធានឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី៩ ខែមីនា ឆ្នាំ២០២០ ស្តីពីការគ្រប់គ្រងចំណូលសេវារបស់អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះ កំណត់អំពីគោលការណ៍និងនីតិវិធីបន្ថែមសម្រាប់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធក្នុងក្របខ័ណ្ឌនៃការផ្ទេរមុខងារចំពោះចំណូលពីសេវាសាធារណៈ ចំណូលពីការពិន័យនិងការដាក់ទណ្ឌកម្ម និងក្នុងក្របខ័ណ្ឌនៃការចែករំលែកចំណូលពីសេវាសាធារណៈ និងចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ ពីរដ្ឋបាលថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ប្រកបដោយប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាព។

**មាត្រា២ .-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ក្នុងក្របខ័ណ្ឌនៃការផ្ទេរមុខងារចំពោះចំណូលពីសេវាសាធារណៈ ចំណូលពីការពិន័យនិងការដាក់ទណ្ឌកម្ម និងក្នុងក្របខ័ណ្ឌនៃការចែករំលែកចំណូលពីសេវាសាធារណៈ និងចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ ពីរដ្ឋបាលថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា៣ .-**

វាក្យសព្ទសំខាន់ៗដែលប្រើសម្រាប់គោលដៅនៃអនុក្រឹត្យនេះ ត្រូវបានកំណត់និយមន័យ ដូចមានចែងនៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

## ជំពូកទី២

## គោលការណ៍រួមនៃការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធក្នុងក្របខ័ណ្ឌនៃការផ្ទេរមុខងារ និង ការបែងចែករំលែកចំណូលមិនមែនសារពើពន្ធ ពីរដ្ឋបាលថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ

**មាត្រា៤ .-**

មុខសញ្ញាចំណូលមិនមែនសារពើពន្ធ ក្នុងក្របខ័ណ្ឌនៃការផ្ទេរមុខងារ និងការបែងចែករំលែកចំណូលមិនមែនសារពើពន្ធ ពីរដ្ឋបាលថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ រួមមាន ចំណូលពីសេវាសាធារណៈ ចំណូលពីការពិន័យ និងការដាក់ទណ្ឌកម្ម ចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ និង/ ឬ ចំណូលមិនមែនសារពើពន្ធផ្សេងទៀត តាមការសម្រេចរបស់រាជរដ្ឋាភិបាល។

ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ក្នុងក្របខ័ណ្ឌនៃការផ្ទេរមុខងារ និងការបែងចែករំលែកចំណូលមិនមែនសារពើពន្ធ ពីរដ្ឋបាលថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ អាចត្រូវបានធ្វើឡើងតាមរយៈ÷

- ការផ្ទេរសិទ្ធិអំណាចជូនរដ្ឋបាលថ្នាក់ក្រោមជាតិ ពាក់ព័ន្ធនឹងការគ្រប់គ្រងនិងប្រមូលចំណូលមិនមែនសារពើពន្ធផ្សារភ្ជាប់មុខងារដែលបានផ្ទេរពីរដ្ឋបាលថ្នាក់ជាតិ ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងរូបភាពជាការប្រគល់មុខងារ ឬ ការធ្វើប្រតិភូកម្មមុខងារ
- ការបែងចែករំលែកចំណូលមិនមែនសារពើពន្ធពីរដ្ឋបាលថ្នាក់ជាតិ ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ
- ទម្រង់ផ្សេងទៀត តាមការសម្រេចរបស់រាជរដ្ឋាភិបាល។

## ជំពូកទី៣

## គោលការណ៍និងនីតិវិធី នៃការគ្រប់គ្រងចំណូលពីសេវាសាធារណៈ និង ចំណូលពីការពិន័យនិងការដាក់ទណ្ឌកម្ម ក្នុងក្របខ័ណ្ឌនៃការប្រគល់មុខងារ

### ផ្នែកទី១

### គោលការណ៍

**មាត្រា៥ .-**

រដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅដែលទទួលបានការប្រគល់មុខងារគ្រប់គ្រង និងប្រមូលចំណូលពីប្រភេទសេវាសាធារណៈ ឬ ប្រភេទអំពើល្មើសមួយចំនួន ពីក្រសួង ស្ថាប័ន នឹងក្លាយជាម្ចាស់មុខងារថ្មី។

**មាត្រា៦ .-**

ប្រភេទសេវាសាធារណៈ ឬ ប្រភេទអំពើល្មើសដែលក្រសួង ស្ថាប័នបានប្រគល់មុខងារគ្រប់គ្រង និងប្រមូលចំណូលទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវលុបចេញពីកម្រងសេវាសាធារណៈ ឬ បញ្ជីផាកពិន័យ នៃប្រកាសអន្តរ-ក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួង ឬ ប្រធានស្ថាប័នដែលមានការពាក់ព័ន្ធ។

ក្រសួង ស្ថាប័នដែលបានប្រគល់មុខងារគ្រប់គ្រង និងប្រមូលចំណូលពីប្រភេទសេវាសាធារណៈ ឬ ប្រភេទអំពើល្មើស ត្រូវរៀបចំកែសម្រួលប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួង ឬ

ប្រធានស្ថាប័នដែលមានការពាក់ព័ន្ធ។ គំរូប្រកាសអន្តរក្រសួង ត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ប្រភេទសេវាសាធារណៈ ឬ ប្រភេទអំពើល្មើសដែលក្រសួង ស្ថាប័នបានប្រគល់មុខងារគ្រប់គ្រង និងប្រមូលចំណូលទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវដាក់បញ្ចូលទៅក្នុងកម្រងសេវាសាធារណៈ ឬ បញ្ជីផាកពិន័យរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា៧ .-**

រដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅដែលទទួលបានការប្រគល់មុខងារគ្រប់គ្រង និងប្រមូលចំណូលពីប្រភេទសេវាសាធារណៈ ឬ ប្រភេទអំពើល្មើស ត្រូវអនុវត្តការប្រមូលចំណូលផ្អែកតាមតម្លៃសេវា ឬ កម្រិតទឹកប្រាក់ផាកពិន័យដែលកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ ក្នុងករណីមានការកែប្រែតម្លៃសេវា ឬ កម្រិតទឹកប្រាក់ផាកពិន័យ ត្រូវមានការពិគ្រោះយោបល់ពីក្រសួង ស្ថាប័នដែលមានការពាក់ព័ន្ធ។

**មាត្រា៨ .-**

ករណីបុគ្គលប្រព្រឹត្តល្មើសមានការរឹងរូសមិនព្រមបង់ប្រាក់ផាកពិន័យ ហើយករណីនេះត្រូវបានរដ្ឋបាលថ្នាក់ក្រោមជាតិ បញ្ជូនសំណុំរឿងទៅសាលាជម្រះក្តី ចំណូលដែលប្រមូលបានដោយអនុវត្តតាមសេចក្តីសម្រេចរបស់សាលាជម្រះក្តី ត្រូវកត់ត្រាជាចំណូលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានសមត្ថកិច្ចផាកពិន័យ។

ករណីរដ្ឋបាលថ្នាក់ក្រោមជាតិ បញ្ជូនសំណុំរឿងទៅសាលាជម្រះក្តី ចំពោះប្រភេទបទល្មើសព្រហ្មទណ្ឌ ចំណូលពីការផ្តន្ទាទោសពិន័យជាប្រាក់ដែលសម្រេចដោយសាលាជម្រះក្តី ត្រូវកត់ត្រាជាចំណូលរបស់រដ្ឋបាលថ្នាក់-ក្រោមជាតិដែលមានសមត្ថកិច្ច។

## ផ្នែកទី២

## នីតិវិធី នៃការរៀបចំគម្រោងចំណូល និងការអនុវត្តការប្រមូលចំណូល

**មាត្រា៩ .-**

រដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅដែលទទួលបានការប្រគល់មុខងារលើការគ្រប់គ្រង និងការប្រមូលចំណូលពីប្រភេទសេវាសាធារណៈ ឬ ចំណូលពីប្រភេទអំពើល្មើស ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម÷

**ដំណាក់កាលរៀបចំគម្រោងចំណូល**

- គ្រោងឥណទានចំណូល ១០០(មួយរយ) ភាគរយ នៅក្នុងគម្រោងចំណូលថវិកាប្រចាំឆ្នាំរបស់ខ្លួន
- រៀបចំគម្រោងតម្រូវការបរិមាណបង្កាន់ដៃបង់ប្រាក់ប្រចាំឆ្នាំ សម្រាប់ការប្រមូលចំណូលប្រចាំឆ្នាំដែលបានគ្រោង។

**ដំណាក់កាលអនុវត្តការប្រមូលចំណូល**

- ប្រើប្រាស់បង្កាន់ដៃបង់ប្រាក់របស់រដ្ឋបាលសាមី ដែលបោះពុម្ព និងបើកផ្តល់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងករណីទទួលចំណូលដោយផ្ទាល់ជាសាច់ប្រាក់ ឬ ជាមូលប្បទានបត្រ។ ក្នុងករណីទូទាត់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក មិនតម្រូវឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់នេះទេ
- ទទួលប័ណ្ណបង់ប្រាក់ ឬ ប្រកាសឥណទានចេញដោយធនាគារពាណិជ្ជ ឬ ភ្នាក់ងារផ្ទេរប្រាក់ផ្សេងទៀត ក្នុងករណីទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក
- បែងចែកចំណូលប្រមូលបានប្រចាំខែ ផ្អែកតាមអត្រា និងមុខសញ្ញាគោលដៅនីមួយៗ ទៅតាមគោល-ការណ៍ដែលកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## ផ្នែកទី៣
## ការកត់ត្រាតាមដាន និងការរៀបចំរបាយការណ៍

**មាត្រា១០ .-**

រដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅដែលទទួលបានការប្រគល់មុខងារគ្រប់គ្រង និងប្រមូលចំណូលពីប្រភេទសេវាសាធារណៈ ឬ ប្រភេទអំពើល្មើស ត្រូវទទួលខុសត្រូវលើការទុកដាក់ថែរក្សាលិខិតយុត្តិការ និងកាន់កាប់បញ្ជីគណនេយ្យដោយចុះកិច្ចបញ្ជិកាទ្វេភាគនូវរាល់កិច្ចប្រតិបត្តិការដែលកើតឡើងប្រចាំថ្ងៃ ទៅតាមនីតិវិធីគ្រប់គ្រងរជ្ជទេយ្យចំណូលសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ និងនីតិវិធីពាក់ព័ន្ធដទៃទៀត តាមការកំណត់របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា១១ .-**

រៀងរាល់ដំណាច់ខែ រដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅដែលទទួលបានការប្រគល់មុខងារគ្រប់គ្រង និងប្រមូលចំណូលលើប្រភេទសេវាសាធារណៈ ឬ ប្រភេទអំពើល្មើស ត្រូវផ្ញើប័ណ្ណបង់ប្រាក់ និងសលាកប័ត្រចំណូលថវិកាថ្នាក់ក្រោមជាតិ ដែលជាច្បាប់ថតចម្លងចំនួនមួយច្បាប់ ទៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ដើម្បីតាមដានការអនុវត្តចំណូល។

**មាត្រា១២ .-**

រដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅដែលទទួលបានការប្រគល់មុខងារគ្រប់គ្រង និងប្រមូលចំណូលពីប្រភេទសេវាសាធារណៈ ឬ ប្រភេទអំពើល្មើស ត្រូវធ្វើរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំស្តីពីស្ថានភាពនៃការអនុវត្តចំណូល ដូចប្រភេទចំណូលដែលជាមុខងារផ្ទាល់របស់ខ្លួន រួចផ្ញើទៅមន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត និងផ្ញើទៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រាជធានី ខេត្ត ដើម្បីធ្វើរបាយការណ៍បូកសរុប ឱ្យបានមុន÷

- ថ្ងៃទី១៥ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ
- ថ្ងៃទី១៥ នៃខែដើមត្រីមាសបន្ទាប់ សម្រាប់របាយការណ៍ប្រចាំត្រីមាស

- ថ្ងៃទី១៥ ខែកក្កដា សម្រាប់របាយការណ៍ប្រចាំឆមាសទី១ និង
- ថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

គំរូរបាយការណ៍ ត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៤
## គោលការណ៍និងនីតិវិធី នៃការគ្រប់គ្រងចំណូលពីសេវាសាធារណៈ និង ចំណូលពីការពិន័យនិងការដាក់ទណ្ឌកម្មក្នុងក្របខ័ណ្ឌនៃការធ្វើប្រតិភូកម្មមុខងារ

### ផ្នែកទី១
### គោលការណ៍

**មាត្រា១៣ .-**

ក្រសួង ស្ថាប័នដែលធ្វើប្រតិភូកម្មមុខងារគ្រប់គ្រង និងប្រមូលចំណូលពីប្រភេទសេវាសាធារណៈ ឬ ប្រភេទអំពើល្មើស ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ នៅតែរក្សាភាពជាម្ចាស់លើមុខងារនោះដដែល។

**មាត្រា១៤ .-**

ប្រភេទសេវាសាធារណៈ ឬ ប្រភេទអំពើល្មើស ដែលក្រសួង ស្ថាប័នបានធ្វើប្រតិភូកម្មមុខងារគ្រប់គ្រង និងប្រមូលចំណូលទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ នៅតែត្រូវបានរក្សាទុកនៅក្នុងកម្រងសេវាសាធារណៈ ឬ បញ្ជីផាកពិន័យរបស់ក្រសួង ស្ថាប័នសាមី ដែលកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួង ឬ ប្រធានស្ថាប័នដែលមានការពាក់ព័ន្ធ។ គំរូប្រកាសអន្តរក្រសួង ត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា១៥ .-**

រដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅដែលទទួលបានប្រតិភូកម្មមុខងារគ្រប់គ្រង និងប្រមូលចំណូលពីប្រភេទសេវាសាធារណៈ ឬ ប្រភេទអំពើល្មើស ត្រូវអនុវត្តការប្រមូលចំណូលផ្អែកតាមតម្លៃសេវា ឬ កម្រិតទឹកប្រាក់ផាកពិន័យ ដែលកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួង ឬ ប្រធានស្ថាប័នដែលមានការពាក់ព័ន្ធ។ ក្នុងករណីមានការកែប្រែតម្លៃសេវា ឬ កម្រិតទឹកប្រាក់ផាកពិន័យ ត្រូវមានការចូលរួមពិគ្រោះយោបល់ពីក្រសួងមហាផ្ទៃ។

### ផ្នែកទី២
### នីតិវិធី នៃការរៀបចំគម្រោងចំណូល និងការអនុវត្តការប្រមូលចំណូល

**មាត្រា១៦ .-**

រដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅដែលទទួលបានប្រតិភូកម្មមុខងារគ្រប់គ្រង និងប្រមូលចំណូលពីប្រភេទសេវាសាធារណៈ ឬ ប្រភេទអំពើល្មើស ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម÷

**ដំណាក់កាលរៀបចំគម្រោងចំណូល**

- គ្រោងឥណទានចំណូល ១០០ (មួយរយ) ភាគរយ នៅក្នុងគម្រោងចំណូលថវិកាប្រចាំឆ្នាំរបស់ខ្លួន
- រៀបចំគម្រោងតម្រូវការបរិមាណបង្កាន់ដៃបង់ប្រាក់ប្រចាំឆ្នាំ សម្រាប់ការប្រមូលចំណូលប្រចាំឆ្នាំដែលបានគ្រោង។

**ដំណាក់កាលអនុវត្តការប្រមូលចំណូល**

- ប្រើប្រាស់បង្កាន់ដៃបង់ប្រាក់របស់រដ្ឋបាលសាមី ដែលបោះពុម្ព និងបើកផ្តល់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងករណីទទួលចំណូលដោយផ្ទាល់ជាសាច់ប្រាក់ ឬ ជាមូលប្បទានបត្រ។ ក្នុងករណីទូទាត់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក មិនតម្រូវឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់នេះទេ
- ទទួលប័ណ្ណបង់ប្រាក់ ឬ ប្រកាសឥណទានចេញដោយធនាគារពាណិជ្ជ ឬ ភ្នាក់ងារផ្ទេរប្រាក់ផ្សេងទៀត ក្នុងករណីទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក
- បែងចែកចំណូលប្រមូលបានប្រចាំខែ ផ្អែកតាមអត្រា និងមុខសញ្ញាគោលដៅនីមួយៗ ទៅតាមគោលការណ៍ដែលកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួង ឬ ប្រធានស្ថាប័នដែលមានការពាក់ព័ន្ធ។

## ផ្នែកទី៣
## ការកត់ត្រាតាមដាន និងការរៀបចំរបាយការណ៍

**មាត្រា១៧ .-**

រដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅដែលទទួលបានប្រតិភូកម្មមុខងារគ្រប់គ្រង និងប្រមូលចំណូលពីប្រភេទសេវាសាធារណៈ ឬ ប្រភេទអំពើល្មើស ត្រូវទទួលខុសត្រូវលើការទុកដាក់ថែរក្សាលិខិតយុត្តិការ និងកាន់កាប់បញ្ជីគណនេយ្យដោយចុះកិច្ចបញ្ជិកាទ្វេភាគនូវរាល់កិច្ចប្រតិបត្តិការដែលកើតឡើងប្រចាំថ្ងៃ ទៅតាមនីតិវិធី នៃការគ្រប់គ្រងរជ្ជទេយ្យចំណូលសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ និងនីតិវិធីពាក់ព័ន្ធដទៃទៀត តាមការកំណត់របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា១៨ .-**

រៀងរាល់ដំណាច់ខែ រដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅដែលទទួលបានប្រតិភូកម្មមុខងារគ្រប់គ្រង និងប្រមូលចំណូលពីប្រភេទសេវាសាធារណៈ ឬ ប្រភេទអំពើល្មើស ត្រូវផ្ញើប័ណ្ណបង់ប្រាក់និងសលាកប័ត្រចំណូលថវិកាថ្នាក់ក្រោមជាតិដែលជាច្បាប់ថតចម្លងចំនួនមួយច្បាប់ ទៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ដើម្បីតាមដានការអនុវត្តចំណូល។

**មាត្រា១៩ .-**

រដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅដែលទទួលបានប្រតិភូកម្មមុខងារគ្រប់គ្រង និងប្រមូលចំណូលពីប្រភេទសេវាសាធារណៈ ឬ ប្រភេទអំពើល្មើស ត្រូវធ្វើរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំស្តីពី

ស្ថានភាពនៃការអនុវត្តចំណូល ទៅមន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត នៃក្រសួង ស្ថាប័នដែលជាម្ចាស់មុខងារ និង មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ឱ្យបានមុន÷

- ថ្ងៃទី១៥ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ
- ថ្ងៃទី១៥ នៃខែដើមត្រីមាសបន្ទាប់ សម្រាប់របាយការណ៍ប្រចាំត្រីមាស
- ថ្ងៃទី១៥ ខែកក្កដា សម្រាប់របាយការណ៍ប្រចាំឆមាសទី១ និង
- ថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

គំរូរបាយការណ៍ ត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត នៃក្រសួង ស្ថាប័នដែលជាម្ចាស់មុខងារ ត្រូវធ្វើរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំស្តីពីស្ថានភាពនៃការអនុវត្តចំណូលពីប្រភេទសេវាសាធារណៈ ឬ ប្រភេទ អំពើល្មើសដែលបានធ្វើប្រតិភូកម្មមុខងារនោះ ផ្ញើទៅក្រសួង ស្ថាប័នរបស់ខ្លួន ឱ្យបានមុន÷

- ថ្ងៃទី២០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ
- ថ្ងៃទី២០ នៃខែដើមត្រីមាសបន្ទាប់ សម្រាប់របាយការណ៍ប្រចាំត្រីមាស
- ថ្ងៃទី២០ ខែកក្កដា សម្រាប់របាយការណ៍ប្រចាំឆមាសទី១ និង
- ថ្ងៃទី២០ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

គំរូរបាយការណ៍ ត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៥
## គោលការណ៍និងនីតិវិធី នៃការគ្រប់គ្រងការបែងចែកចំណូលពីសេវាសាធារណៈ

### ផ្នែកទី១
### គោលការណ៍

**មាត្រា២០ .-**

ការបែងចែកចំណូលពីសេវាសាធារណៈ សំដៅត្រឹមការបែងចែកចំណូលពីសេវាសាធារណៈ ស្ថិតក្នុង មុខងារគ្រប់គ្រង និងប្រមូលចំណូលដោយក្រសួង ស្ថាប័ននៅរដ្ឋបាលកណ្តាល ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ក្រៅពី ប្រភេទចំណូលពីសេវាសាធារណៈដែលបានផ្ទេរមុខងាររួចហើយ ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ និងចំណូលពីសេវា សាធារណៈ ដែលប្រមូលនៅមន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត។

ក្រសួង ស្ថាប័នដែលប្រមូលចំណូលពីសេវាសាធារណៈ ត្រូវបន្តគ្រប់គ្រងទាំងស្រុងលើចំណូលពីសេវា សាធារណៈ ដែលត្រូវបែងចែកទៅរដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅ។

**មាត្រា២១ .-**

ចំណូលពីសេវាសាធារណៈដូចមានចែងនៅក្នុងមាត្រា២០ នៃអនុក្រឹត្យនេះ ត្រូវអនុវត្តតាមអត្រាចែករំលែក ដែលកំណត់ដោយរាជរដ្ឋាភិបាល។ ចំណែកនៃចំណូលពីសេវាសាធារណៈ ដែលត្រូវផ្ទេរជាគុណប្រយោជន៍ដល់

ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវអនុវត្តតាមយន្តការ «**មូលនិធិភាតរភាព**»។ ការរៀបចំ និងការប្រព្រឹត្តទៅរបស់ «**មូលនិធិភាតរភាព**» ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា២២ .-**

តាមរយៈយន្តការ «**មូលនិធិភាតរភាព**» អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រៀបចំវិភាជថវិកាដល់រដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅនីមួយៗ ក្នុងនោះការយកចិត្តទុកដាក់ខ្ពស់ត្រូវផ្តល់លើរដ្ឋបាលក្រុង ស្រុក និង រដ្ឋបាលឃុំ សង្កាត់ នៅក្នុងការគ្រោងចំណូល និងឥណទានចំណាយថវិកា នៅក្នុងសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ។

## ផ្នែកទី២

## នីតិវិធី នៃការរៀបចំគម្រោងចំណូល និងការអនុវត្តការប្រមូលចំណូល

**មាត្រា២៣ .-**

ក្រសួង ស្ថាប័ន ដែលត្រូវចែករំលែកចំណូលពីសេវាសាធារណៈ ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវ÷

**ដំណាក់កាលរៀបចំគម្រោងចំណូល**

- គ្រោងឥណទានចំណូល ១០០(មួយរយ) ភាគរយ នៅក្នុងគម្រោងចំណូលថវិកាប្រចាំឆ្នាំរបស់ខ្លួន
- គ្រោងឥណទានចំណាយលើទឹកប្រាក់ចំណូល ដែលគ្រោងចែករំលែកទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈមូលនិធិភាតរភាព ទៅតាមអត្រាដែលកំណត់ដោយរាជរដ្ឋាភិបាល។ ការគណនារកឥណទានចំណាយនេះ ត្រូវផ្អែកទៅតាមសមាមាត្រនៃចំណែកសាច់ប្រាក់ដែលត្រូវបង់ចូលគណនីទោលរតនាគារ ដូចមានចែងក្នុងប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួង ឬប្រធានស្ថាប័នដែលមានការពាក់ព័ន្ធ ទៅតាមមុខសញ្ញាចំណូលពីសេវាសាធារណៈ ដែលបានគ្រោង ក្នុងគម្រោងចំណូលថវិកាប្រចាំឆ្នាំរបស់ខ្លួន
- រៀបចំគម្រោងតម្រូវការបរិមាណបង្កាន់ដៃបង់ប្រាក់ប្រចាំឆ្នាំ សម្រាប់ការប្រមូលចំណូលប្រចាំឆ្នាំដែលបានគ្រោង។

**ដំណាក់កាលអនុវត្តការប្រមូលចំណូល**

- ប្រើប្រាស់បង្កាន់ដៃបង់ប្រាក់របស់ក្រសួង ស្ថាប័នសាមី ដែលបោះពុម្ព និងបើកផ្តល់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងករណីទទួលចំណូលដោយផ្ទាល់ជាសាច់ប្រាក់ ឬ ជាមូលប្បទានបត្រ។ ក្នុងករណីទូទាត់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក មិនតម្រូវឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់នេះទេ
- ទទួលប័ណ្ណបង់ប្រាក់ ឬ ប្រកាសឥណទានចេញដោយធនាគារពាណិជ្ជ ឬ ភ្នាក់ងារផ្ទេរប្រាក់ផ្សេងទៀតក្នុងករណីទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក
- ផ្ទេរចំណូលចែករំលែកទៅក្នុងមូលនិធិភាតរភាព ផ្អែកតាមអត្រាដែលកំណត់ដោយរាជរដ្ឋាភិបាល។ ការគណនារកចំណូលដែលត្រូវផ្ទេរចូលមូលនិធិភាតរភាព ត្រូវផ្អែកទៅតាមសមាមាត្រនៃចំណែកសាច់-

ប្រាក់ដែលបានបង់ចូលគណនីទោលរតនាគារជាក់ស្តែង ដោយក្រសួង ស្ថាប័នដែលមានការពាក់ព័ន្ធទៅតាមមុខសញ្ញាចំណូលពីសេវាសាធារណៈដែលប្រមូលបានប្រចាំឆ្នាំជាក់ស្តែង

- ជារៀងរាល់ដំណាច់ឆមាស ត្រូវបោះផ្សាយអាណត្តិបើកប្រាក់ ដើម្បីកត់ត្រាចំណាយទឹកប្រាក់ចំណូលជាក់ស្តែង ដែលត្រូវចែករំលែក និងផ្ទេរចូលមូលនិធិភាតរភាព
- ក្នុងករណីចំណូលប្រមូលបានលើសផែនការ ក្រសួង ស្ថាប័នត្រូវស្នើសុំបន្ថែមឥណទាន ដើម្បីបោះផ្សាយអាណត្តិបើកប្រាក់ ផ្ទេរចូលមូលនិធិភាតរភាព។

## ផ្នែកទី៣

## ការកត់ត្រាតាមដាន និងការរៀបចំរបាយការណ៍

**មាត្រា២៤ .-**

ក្រសួង ស្ថាប័ន ដែលចែករំលែកចំណូលពីសេវាសាធារណៈ ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលខុសត្រូវលើការទុកដាក់ថែរក្សាលិខិតយុត្តិការ និងកាន់កាប់បញ្ជីគណនេយ្យដោយចុះកិច្ចបញ្ជិកាទ្វេភាគនូវរាល់កិច្ចប្រតិបត្តិការដែលកើតឡើងប្រចាំថ្ងៃ ទៅតាមនីតិវិធីគ្រប់គ្រងរជ្ជទេយ្យចំណូលសម្រាប់រដ្ឋបាលថ្នាក់ជាតិ តាមការកំណត់របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា២៥ .-**

ក្រសួង ស្ថាប័ន ដែលចែករំលែកចំណូលពីសេវាសាធារណៈ ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវធ្វើរបាយការណ៍អនុវត្តចំណូលដែលត្រូវចែករំលែក ដោយឆ្លុះបញ្ចាំងនូវទឹកប្រាក់ជាក់ស្តែងដែលបានចែករំលែក និងបានផ្ទេរចូលមូលនិធិភាតរភាព ផ្ញើទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឱ្យបានមុន÷

- ថ្ងៃទី១៥ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ
- ថ្ងៃទី១៥ នៃខែដើមត្រីមាសបន្ទាប់ សម្រាប់របាយការណ៍ប្រចាំត្រីមាស
- ថ្ងៃទី១៥ ខែកក្កដា សម្រាប់របាយការណ៍ប្រចាំឆមាសទី១ និង
- ថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

គំរូរបាយការណ៍ ត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៦

## គោលការណ៍និងនីតិវិធី នៃការគ្រប់គ្រងការចែករំលែកចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ

## ផ្នែកទី១

## គោលការណ៍

**មាត្រា២៦ .-**

ចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋដែលមានការចែករំលែកពីរដ្ឋបាលថ្នាក់ជាតិ ទៅឱ្យរដ្ឋបាលថ្នាក់-ក្រោមជាតិ រួមមាន ចំណូលពីសម្បទាននេសាទ ចំណូលពីការជួលទ្រព្យសម្បត្តិរដ្ឋរបស់មន្ទីរជំនាញរាជធានី ខេត្ត



ម៩

ចំណូលពីសម្បទានដីសេដ្ឋកិច្ច ចំណូលពីផលព្រៃឈើ និង/ឬ ចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋផ្សេងទៀត ដែលមានការសម្រេចពីរាជរដ្ឋាភិបាល។

ចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ ដូចមានចែងក្នុងកថាខណ្ឌទី១ ត្រូវអនុវត្តតាមអត្រាចែករំលែកដែលកំណត់ដោយរាជរដ្ឋាភិបាល។

ចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋដែលត្រូវចែករំលែកទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវផ្តល់ជូនមួយចំណែកជូនរដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅ ដែលចូលរួមកៀរគរចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋដែលស្ថិតក្នុងដែនសមត្ថកិច្ចរដ្ឋបាលសាមី។ ចំណូលចែករំលែកមួយចំណែកទៀត ត្រូវផ្ទេរជាគុណប្រយោជន៍ដល់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ដោយអនុវត្តតាមយន្តការ «**មូលនិធិភាតរភាព**»។ អត្រានៃការបែងចែកចំណូលចែករំលែករវាងរដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅ និងតាមរយៈយន្តការ«**មូលនិធិភាតរភាព**» ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយមានការពិគ្រោះយោបល់ជាមួយក្រសួងមហាផ្ទៃ។

**មាត្រា២៧ .-**

មុខងារ និងភារកិច្ចក្នុងការគ្រប់គ្រងចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ នៃរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវអនុវត្តតាមដែនសមត្ថកិច្ចដូចមានចែងក្នុងឯកសារគតិយុត្តនានា សម្រាប់ការប្រមូលចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ និងបទប្បញ្ញត្តិជាធរមានស្តីពីការគ្រប់គ្រងចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ។

ក្រសួង ស្ថាប័ន ដែលចែករំលែកចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំប្រកាសអន្តរក្រសួងជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការបែងចែកចំណូលជូនរដ្ឋបាលថ្នាក់ក្រោមជាតិ។

## ផ្នែកទី២
## នីតិវិធីនៃការរៀបចំគម្រោងចំណូល និងការអនុវត្តការប្រមូលចំណូល

**មាត្រា២៨ .-**

ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅ ត្រូវ÷

**ដំណាក់កាលរៀបចំគម្រោងចំណូល**

- ក្រសួង ស្ថាប័នដែលចែករំលែកចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅ ត្រូវគ្រោងចំណូលដែលនៅសល់ក្រោយការចែករំលែកឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅទៅក្នុងគម្រោងចំណូលថវិកាប្រចាំឆ្នាំរបស់ខ្លួន
- ក្រសួង ស្ថាប័ន ត្រូវគ្រោងឥណទានចំណាយលើទឹកប្រាក់ចំណូល ដែលគ្រោងចែករំលែក និងផ្ទេរទៅមូលនិធិភាតរភាព ទៅតាមអត្រាដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- រដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅដែលទទួលបានចំណូលពីការចែករំលែកចំណូលពីការចាត់ចែងទ្រព្យ-សម្បត្តិរដ្ឋ ត្រូវគ្រោងចំណូលពីការចែករំលែកទាំងនោះ ផ្អែកតាមអត្រាដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទៅក្នុងគម្រោងចំណូលថវិកាប្រចាំឆ្នាំរបស់ខ្លួន។

**ដំណាក់កាលអនុវត្តការប្រមូលចំណូល**

- ក្រសួង ស្ថាប័នដែលចែករំលែកចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅ ត្រូវប្រមូលចំណូល ១០០ (មួយរយ) ភាគរយ និងចាត់ចែងការបង់ចំណូល ផ្អែកតាមអត្រា និងមុខសញ្ញាគោលដៅនីមួយៗ ស្របតាមគោលការណ៍កំណត់ដោយរាជរដ្ឋាភិបាល
- ជារៀងរាល់ដំណាច់ឆមាស ក្រសួង ស្ថាប័ន ត្រូវបោះផ្សាយអាណត្តិបើកប្រាក់ ដើម្បីកត់ត្រាចំណាយទឹកប្រាក់ចំណូលជាក់ស្តែង ដែលត្រូវចែករំលែក និងផ្ទេរចូលមូលនិធិភាគរភាព
- រដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅ ដែលទទួលបានការចែករំលែកចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋពីក្រសួង ស្ថាប័ន ត្រូវតាមដានការបង់ចំណូលចែករំលែកដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលគោលដៅសាមី
- ក្នុងករណីចំណូលប្រមូលបានលើសផែនការ ក្រសួង ស្ថាប័ន ត្រូវស្នើសុំបន្ថែមឥណទានចំណាយ ដើម្បីបោះផ្សាយអាណត្តិបើកប្រាក់ ផ្ទេរចូលមូលនិធិភាគរភាព។

## ផ្នែកទី៣
## ការកត់ត្រាតាមដាន និងការរៀបចំរបាយការណ៍

**មាត្រា២៩ .-**

ផ្អែកតាមតួលេខបង់ចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋនៅអគ្គនាយកដ្ឋានរតនាគារជាតិ ក្រសួង ស្ថាប័នដែលប្រមូលចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ ត្រូវធ្វើរបាយការណ៍អំពីការបង់ចំណូល ផ្ញើជូនអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ និងអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឱ្យបានមុន÷

- ថ្ងៃទី១៥ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ
- ថ្ងៃទី១៥ នៃខែដើមត្រីមាសបន្ទាប់ សម្រាប់របាយការណ៍ប្រចាំត្រីមាស
- ថ្ងៃទី១៥ ខែកក្កដា សម្រាប់របាយការណ៍ប្រចាំឆមាសទី១ និង
- ថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

គំរូរបាយការណ៍ ត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ផ្អែកតាមតួលេខបង់ចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋនៅរតនាគាររាជធានី ខេត្ត រដ្ឋបាលថ្នាក់ក្រោម-ជាតិគោលដៅដែលទទួលចំណូលចែករំលែកពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ ត្រូវធ្វើរបាយការណ៍អំពីការបង់ចំណូលផ្ញើជូនសាមីក្រសួង ស្ថាប័នដែលចែករំលែកចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ និងផ្ញើជូនអគ្គនាយកដ្ឋានទ្រព្យ-សម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ និងអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឱ្យបានមុន÷

- ថ្ងៃទី២០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ
- ថ្ងៃទី២០ នៃខែដើមត្រីមាសបន្ទាប់ សម្រាប់របាយការណ៍ប្រចាំត្រីមាស

- ថ្ងៃទី២០ ខែកក្កដា សម្រាប់របាយការណ៍ប្រចាំឆមាសទី១ និង
- ថ្ងៃទី២០ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

គំរូរបាយការណ៍ ត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៧

## សន្ធានកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រង និងប្រមូលចំណូលមិនមែនសារពើពន្ធ

**មាត្រា៣០ ._**

រាល់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលបង្កើតឡើងដោយក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ពាក់ព័ន្ធនឹងការប្រមូលចំណូលមិនមែនសារពើពន្ធត្រូវមានការចូលរួមពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីធានាអំពីការធ្វើសន្ធានកម្មទិន្នន័យ ជាមួយប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងផ្លាស់ប្តូរទិន្នន័យតាមរយៈថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា។

ក្រសួង ស្ថាប័នដែលប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ផ្តល់សេវាសាធារណៈ ត្រូវធ្វើសន្ធានកម្មទិន្នន័យជាមួយប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រង និងផ្តល់សេវាសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ចំពោះប្រភេទសេវាសាធារណៈដែលបានប្រគល់ ឬ ប្រតិភូកម្មមុខងារគ្រប់គ្រងនិងប្រមូលចំណូល ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។

## ជំពូកទី៨

## អន្តរប្បញ្ញត្តិ

**មាត្រា៣១._**

ក្នុងរយៈពេលអន្តរកាល រដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅដែលទទួលបានការផ្ទេរមុខងារគ្រប់គ្រង និងប្រមូលចំណូលពីប្រភេទសេវាសាធារណៈ ឬ ប្រភេទអំពើល្មើស អាចអនុវត្តការប្រមូលចំណូលជាបណ្តោះអាសន្នផ្អែកតាមតម្លៃសេវា ឬ កម្រិតទឹកប្រាក់ផាកពិន័យ ដែលកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួង ឬ ប្រធានស្ថាប័នដែលមានការពាក់ព័ន្ធ រហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស។

**មាត្រា៣២._**

ក្រោយអនុក្រឹត្យនេះចូលជាធរមាន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដឹកនាំ និងសម្របសម្រួលជាមួយក្រសួង ស្ថាប័នដែលមានការពាក់ព័ន្ធ រៀបចំ និងកែសម្រួលប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួង ឬ ប្រធានស្ថាប័នដែលមានការពាក់ព័ន្ធ ដោយត្រូវធ្វើនីត្យានុកូលកម្មឡើងវិញ តាមវិធាន និងនីតិវិធីដែលកំណត់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៩
## អវសានប្បញ្ញត្តិ

**មាត្រា៣៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣៤ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១ រោច ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១ ខែកញ្ញា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**កិត្តិទេសាភិបាលបណ្ឌិត ហ៊ុន ម៉ាណែត**

បានយកសេចក្ដីគោរពជម្រាបជូន

ឯកឧត្ដមកិត្តិទេសាភិបាលបណ្ឌិត នាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល ÷**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ